ទុកក្នុងសំណុំរឿង

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខៈ ៤៧៥ ស.ជ.ណ

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០១១

**សូមគោរពជូន**

**ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ**

**ដែលជាប្រធានស្ថាប័ន នៃរាជរដ្ឋាភិបាល**

**កម្មវត្ថុ ៖** ការធ្វើប្រក្រតីភាពការដំឡើងថ្នាក់ ការដំឡើងឋានន្តរសក្តិ ការផ្លាស់ប្តូរប្រភេទក្របខណ្ឌ និងការតែងតាំងមន្ត្រីរាជការស៊ីវិលឡើងវិញ។

**យោង ៖** - សេចក្តីជូនដំណឹងលេខ ១៤៣៧ ស.ជ.ណ ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០០៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

- ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០១១។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តម លោកជំទាវ មេត្តាជ្រាបថា រាជរដ្ឋាភិបាល បានសម្រេចលើការដំឡើងថ្នាក់ ការដំឡើងឋានន្តរសក្តិ ការផ្លាស់ប្តូរប្រភេទក្របខណ្ឌ និងការតែងតាំងមន្ត្រីរាជការស៊ីវិល ដូចខាងក្រោម ៖

១- អនុញ្ញាតឲ្យធ្វើប្រក្រតីភាពឡើងវិញនូវការដំឡើងថ្នាក់ ការដំឡើងឋានន្តរសក្តិ ការផ្លាស់ប្តូរប្រភេទក្របខណ្ឌ ការដំឡើងកម្រិតប្រាក់បំណាច់មុខងារតាមអតីតភាព និងការតែងតាំងមន្ត្រីរាជការស៊ីវិល ចាប់ពីខែមេសា ឆ្នាំ ២០១១ នេះតទៅ។

២-អនុញ្ញាតឲ្យកែសម្រួលថ្នាក់ ឋានន្តរសក្តិ និងប្រភេទក្របខណ្ឌនៅក្នុងតារាងទូទាត់បៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យា ជូនមន្ត្រីរាជការស៊ីវិលដែលទទួលបានការដំឡើងថ្នាក់ ឋានន្តរសក្តិ និងផ្លាស់ប្តូរប្រភេទក្របខណ្ឌដោយការប្រឡងផ្ទៃក្នុង តាមព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស ចាប់ពីខែមករា ឆ្នាំ ២០១១ តទៅ ដោយពុំរំលឹកប្រាក់បៀវត្សជូនឡើយ លើកលែងតែមន្ត្រីរាជការនៃក្រសួងអប់រំ យុវជន និងកីឡា ដែល

បានធ្វើសមាហរណកម្មពីក្រុមហ៊ុនចំការកៅស៊ូ ហើយបានរៀបចំបៀវត្សបណ្ដោះអាសន្ន និងប្រាក់ម៉ោង របស់គ្រូបង្រៀននៅខេត្តកណ្ដាលចំនួន ១២ រូប ត្រូវបានទទួលការផ្ដល់ប្រាក់រំលឹកជូន។

៣- អនុញ្ញាតឲ្យមន្ត្រីរាជការស៊ីវិលដែលបានផ្លាស់ប្ដូរប្រភេទក្របខណ្ឌតាមរយៈការប្រឡងផ្ទៃក្នុង ហើយមានព្រះរាជក្រឹត្យ ឬអនុក្រឹត្យតែងតាំងក្នុងប្រភេទក្របខណ្ឌថ្មី ប៉ុន្តែពុំទាន់បានកែសម្រួលក្នុងតារាងទូទាត់បៀវត្សតាមប្រព័ត៌មានវិទ្យា ដោយសារការបង្កកក្នុងឆ្នាំ ២០១០ ហើយបច្ចុប្បន្នដល់អាយុចូលនិវត្តផ្អែកលើក្របខណ្ឌចាស់ នៅបន្តការងារស្របតាមការតែងតាំងនៃព្រះរាជក្រឹត្យ ឬអនុក្រឹត្យនោះ ។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកជំទាវ មេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

សូមឯកឧត្តម លោកជំទាវ មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**
**និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល**

**សុខ អាន**

__ចម្លងជូន__

- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ឯកសារ - កាលប្បវត្តិ